**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃលំផាត់ ខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការស្នើសុំរបស់ក្រសួងបរិស្ថាន

# សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ ដែលមានផ្ទៃដីសរុបទំហំ ២៥០.០០០ (ពីរសែនប្រាំម៉ឺន) ហិកតា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងនិយាមកា (Datum: WGS1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដើម្បីៈ

- ធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងដែនជម្រកសត្វព្រៃលំផាត់
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់តំបន់ការពារធម្មជាតិ។

**មាត្រា៣.-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី ជា ៤ តំបន់ដែលរួមមានៈ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ សម្រាប់បម្រើដល់ការងារគ្រប់គ្រង ថែរក្សា អភិរក្ស និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តភាព។

១. **តំបន់ស្នូល** មានចំនួន ០២កន្លែង មានផ្ទៃដីសរុប ៤១.៩២០ (បួនម៉ឺនមួយពាន់ប្រាំបួនរយម្ភៃ) ហិកតា តំបន់ស្នូលទី១ (CRZ1) ស្ថិតនៅតំបន់ព្រៃខ្សៀវ និងតំបន់ស្នូលទី២ (CRZ2) ស្ថិតនៅខាងកើតទន្លេស្រែពក ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

២. **តំបន់អភិរក្ស** មានចំនួន ០១កន្លែង មានផ្ទៃដីសរុប ១០៥.២៨៥ (មួយសែនប្រាំពាន់ពីររយប៉ែតសិបប្រាំ) ហិកតា តំបន់នេះលាតសន្ធឹងពីព្រំប្រទល់ដែនជម្រកសត្វព្រៃលំផាត់ប៉ែកខាងលិចទន្លេស្រែពក ហើយឆ្លងកាត់ទន្លេស្រែពកបន្តដល់បែកខាងកើតទន្លេស្រែពក ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

៣. **តំបន់ប្រើប្រាស់ដោយចីរភាព** មានចំនួន ០៤កន្លែង មានផ្ទៃដីសរុប ៧៩.១២៥ (ប្រាំពីរម៉ឺនប្រាំបួនពាន់មួយរយម្ភៃប្រាំ) ហិកតា ដែលរួមមានៈ តំបន់ (SUZ1) ស្ថិតនៅតាមដងទន្លេស្រែពកខាងក្នុង តំបន់ (SUZ2) ស្ថិតនៅជាប់ភាគខាងត្បូងនៃតំបន់សហគមន៍ (CMZ5) ជាទីតាំងដែលប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋានស្នើទុកបង្កើតជាតំបន់សហគមន៍ការពារធម្មជាតិថ្មី តំបន់ (SUZ3) ជាទីតាំងដែលទុកបង្កើតជាតំបន់សហគមន៍ការពារធម្មជាតិថ្មីស្ថិតនៅជាប់នឹងតំបន់សហគមន៍ (CMZ4) និងទន្លេស្រែពក តំបន់ (SUZ4) ស្ថិតនៅភាគខាងលិចនៃតំបន់សហគមន៍ (CMZ7) និងជាទីតាំងដែលទុកបង្កើតជាតំបន់សហគមន៍ការពារធម្មជាតិថ្មី ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

៤. **តំបន់សហគមន៍** មានចំនួន ០៧កន្លែង មានផ្ទៃដីសរុប ២៣.៦៧០ (ពីរម៉ឺនបីពាន់ប្រាំមួយរយចិតសិប) ហិកតា ដែលរួមមានៈ តំបន់សហគមន៍ទី១ (CMZ1) ស្ថិតនៅក្បែរភូមិស្រែពកតូច និងជំតំបន់ទី២ (CMZ2) ស្ថិតនៅក្បែរឃុំសេដា ជាតំបន់ដែលមានភូមិករ និងមានលំនៅដ្ឋានរបស់ប្រជា

ពលរដ្ឋ ហើយក្នុងនោះមានវាលស្រែ និងចំការរបស់ប្រជាជនឃុំសេដា តំបន់ទី៣ (CMZ3) ស្ថិតនៅជាប់ព្រំប្រទល់តំបន់អភិរក្ស តំបន់ទី៤ (CMZ4) ស្ថិតនៅក្បែរភូមិកោះមៀលលើ និងក្រោម តំបន់ទី៥ (CMZ5) ស្ថិតនៅក្បែរឃុំវយ៉ តំបន់ទី៦ (CMZ6) ស្ថិតនៅក្បែរឃុំវាក់ និងតំបន់ទី៧ (CMZ7) ស្ថិតនៅជាប់ភូមិតួន និងស្រែហឿវ ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

**មាត្រា៤** .-

តំបន់គ្រប់គ្រងនីមួយៗក្នុងដែនជម្រកសត្វព្រៃលំផាត់នេះ អាចត្រូវបានធ្វើការកែប្រែក្នុងករណីចាំបាច់ ដោយយោងតាមការសិក្សាស្រាវជ្រាវលើធនធានធម្មជាតិ និងតាមតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៥** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទីកំណត់តំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃលំផាត់ ស្ថិតក្នុងខេត្តមណ្ឌលគិរី និងខេត្តរតនគិរី

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧




ផ្ទៃដីដែនជម្រកសត្វព្រៃលំផាត់ ទំហំសរុប ២៥០០០០ ហិកតា

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

ព្រះរាជាណាចក្រកម្ពុជា

សញ្ញាសម្គាល់

- ព្រំប្រទល់ឃុំ
- តំបន់ស្នូល (៤១ ៩២០ហិកតា)
- តំបន់អភិរក្ស (១០៥ ២៨៥ហិកតា)
- តំបន់ប្រើប្រាស់ដោយចីរភាព (៧៥ ១២៥ហិកតា)
- តំបន់សហគមន៍ (២៣ ៦៧០ហិកតា)
- ព្រំប្រទល់ដែនជម្រកសត្វព្រៃលំផាត់

Map Coordinate System
Unit: meter
System: UTM, Zone 48
Datum: WGS 1984

គម្របព្រៃឈើ ឆ្នាំ២០១៥

- ព្រៃស្រោង
- ព្រៃល្បោះ
- ព្រៃចម្រុះ
- [illegible]
- ចំការ
- ភូមិ
- ដំណាំឧស្សាហកម្ម
- វាលស្មៅ

0 10 20 km